សេកកិច្ច នៃ ចំការកម្ម

សេកកិច្ច នៃ ចំការកម្ម

លោក ហ៊ុន សែន គាត់ កំពុង ធ្វើសេកកិច្ច[1] នៃ ចំការកម្ម របស់គាត់ ដើម្បី បេះផលទុក្ខ សំរាប់ប្រជាពលរដ្ឋខ្មែរ បរិភោគ។ គាត់ មានអារម្មណ៍ ថា បំណាច់[2] របស់គាត់សព្វថ្ងៃ វាជា បារមី នៃ អ្នក មានអំណាច អាចនឹង ការ៉ែ កម្ម អោយទៅជា បុណ្យ។ ដូចនេះ សញ្ញាណ នៃ បុណ្យបាប របស់គាត់ ក៏វាស្ថិត នៅត្រឹមតែ ‹សុខអញ ជាបុណ្យ របស់អញ, ទុក្ខឯង ជាបាប របស់ឯង›។ ចំពោះ លោក ហ៊ុន សែន គំនិត នៃ ករុណា ចំពោះអ្នកទាំងពួង វាជា គំនិត នៃអប្បច្ចយភាព នៅក្នុង រចនាសម្ព័ន្ធ នៃ ចេស្តា របស់អំណាច[3]។ ហើយ រចនាសម្ព័ន្ធនេះឯង ដែលគាត់ យកវា មកបញ្ចូល ទៅក្នុង សញ្ញាណ នៃ លទ្ធិប្រជាធិបតេយ្យ។ ម្លោះ ហើយ គាត់ជឿថា អំណាច របស់គាត់ វា ស្របច្បាប់ មាន ចារ នៅក្នុង រដ្ឋធម្មនុញ្ញ។ ដូច្នេះ ការចាប់ ដាក់គុក លោក កឹម សុ ខា, ហុង សុខហួរ, អ៊ុ សំអាន ដែលមាន អភ័យឯកសិទ្ធ ជា សមាជិកសភា វាជាទង្វើស្របច្បាប់ ចំពោះលោក ហ៊ុន សែន។

---

[1] ធ្វើសេកកិច្ច : ស្រោច។

[2] ពាក្យនេះ មានន័យថាការបានធ្វើអ្វីមួយ១មានថ្ងៃដែលៃ្លកពីអ្នកទាំងពួង។

[3] គំនិត នៃអប្បច្ចយភាព នៅក្នុង រចនាសម្ព័ន្ធ នៃ ចេស្តា របស់អំណាច ; une pensée illogique dans une structure d’autorité du pouvoir។

សេកកិច្ច នៃ ចំការកម្ម

នៅចំពោះមុខអយុត្តិធម៌នេះ ជនជាតិខ្មែរ មានទុក្ខរួម តែពុំអាចលួតគ្នា ជាបាច់កម្លាំង សំរាប់ការពារ សិទ្ធិពលរដ្ឋ។ តែគេដឹងថា ការរំដោះទុក្ខ វាមានតែទ្រឹស្តី ពីរគត់ ដែលត្រូវ យកមកអនុវត្ត : ឬក៏ នាំគ្នាចាប់គ្នាលួត ដោយខ្លួនឯង ជាកម្លាំងរួមដើបឡើង តស៊ូប្រឆាំងនឹងទុក្ខ ឬក៏ មានអ្នកដឹកនាំរៀសអាចនឹងប្រមូលកម្លាំងជាតិ ជាកម្លាំងលួត ដើម្បីតស៊ូ រំដោះទុក្ខ។ ទ្រឹស្តីនោះ វាគ្មានមានសោះ នៅស្រុកខ្មែរសព្វថ្ងៃ ព្រោះប្រជាជនខ្មែរ ក៏ដូច ពួកអ្នកនយោបាយ នាំគ្នាយល់ច្រឡំថា នៅស្រុកខ្មែរសព្វថ្ងៃ ជា ស្រុក អនុវត្ត នូវ លិទ្ធិប្រជាធិបតេយ្យ បើមិន សុក្រិត ក៏វា ជា សេចក្តីសង្ឃឹមដែរ ដូចយ៉ាង មាន ការបោះឆ្នោត ទៀងទាត់ ជ្រើសរើស អ្នកដឹកនាំជាតិ។ ការបោះឆ្នោត គ្មានសេរី គ្មានយុត្តិធម៌ នេះឯង ជា ចំការកម្ម ដែលលោក ហ៊ុន សែន គាត់ដាំ, ហើយ គាត់បញ្ជោតខ្មែរ ក្នុងនោះ មាន ទាំង លោក សម រង្សី និង កឹម សុខា ផង ឲជួយស្រោចឲដំណុះ នៃ ដំណាំ បង្កើតបាន ជាព្រៃកម្ម នៅស្រុកខ្មែរ។ ទាំងអស់គ្នា ដូចជានាំគ្នា បន្សុទ្ធ[4] នូវ សុខ របស់លោក ហ៊ុន សែន ដោយ យកទុក្ខខ្លួន ទៅ បន្សាំ នាំ បង្កើន ចំនួន ជនជាតិយួនពេញស្រុកខ្មែរ។ រីឯ ខ្មែរម្ចាស់ស្រុក វិញ ចេះតែលួមជានិច្ច ព្រោះខ្លាច មានទោស ដូចមានចែង នៅក្នុងច្បាប់ រាជនេតិថា : ‹ *ទោសកើតម្ស៊ីតពោល លួមមាត់[5] ណ្ណានពាន*›។ តែ ការហាមចិត្ត

---

[4] បន្សុទ្ធ : ធ្វើអោយសុទ្ធ។

[5] លួមមាត់ មានន័យថា ដែលចេះតែរអិលមាត់ថាទៅ។

សេកកិច្ច នៃ ចំការកម្ម

កុំ១ ‹ល្ងមមាត់› វាប្រែក្លាយទៅជា ១ ‹ចេះតែចិត្តល្ងម› ដែលជា និមិត្តហេតុ (symptôme) នៃ ទុក្ខ របស់ខ្មែរតែម្តង។ លុះចំណេរ តមក ទុក្ខជាក់ស្តែងនេះ វាក្លាយទៅជា មូលអកុសលខ្មែរ[6] ដោយសារ ចិត្តល្ងម វាក្លាយ ជា ពាក្យ រវេចន:នឹងពាក្យ ប្រតិ បាទន៍ ពោលថា : រន្ទា ឆ្ពោះអ្នកមានអំណាច ទោះបី ជននោះ ជា រសរត្តី[7] ក៏ល្ងមនឹងសំពះ សូមរស់ ព្រោះ តតវាតអាទិ យកអ្វី ទេ។ ដូច្នេះ នាំគ្នា ជជ្រកមមក ទៅ ជួយស្រោច ចំការកម្ម របស់ លោក ហ៊ុន សែន ១ដុះ ជាព្រៃកម្ម ជំនួសព្រៃធម្មជាតិ សំរាប់ ទុកជា ជំរកកម្ម ក៏ចេះតែចិត្តល្ងម នឹងអាចធ្វើបានដែរ អោយ តែមានងារ ជាឯកឧត្តម ទោះបីត្រូវ ពួកអ្នកមានអំណាច ជ ញ្ជាន់ក្បាលក៏ដោយ ដូចលោក សម រង្សី និង កឹម សុខា គាត់ តែងតែប្រព្រឹត្ត អំពើបែបនេះ នៅពេលណា លោក ហ៊ុន សែន ចែកប្រយោជន៍បន្ទិចបន្ទួចដល់គាត់។ ដូច្នេះ ការណ៍នេះ វា ស្របនឹង បុរាណភាសិតថា : ចំណេះ ជិះកងង។ ពួកគាត់ តែង តែនាំគ្នា ស្រែកបន្លឺថា ជិតំ[8] ! តើ ជិតំ តឡរនៅត្រង់ណាទៅ បើ ខ្មែរ អ្នកគាំទ្រគាត់ ចេះតែចិត្តល្ងមរហូត នាំគ្នា ដេកចាំតែបោះ ឆ្នោត សំរាប់ ១យួនជាន់ក នៅក្នុងចំការកម្ម របស់លោក ហ៊ុន សែន ដែល លោក សម រង្សី និង កឹម សុខា ជួយស្រោច ជានិច្ច។

---

[6] មូលអកុសលខ្មែរ ; racine du mal khmer។

[7] រសរត្តី : អ្នកញ្ជាំងគេអោយប្រព្រឹត្តក្នុងអំណាចខ្លួន ឬ អ្នកវាតអំណាច។

[8] ជិតំ ពាក្យសំរាប់ស្រែក ឈ្នះហើយ !។